| ៦-វរសេនីយ៍ឯក | NGUYEN VAN DANH | អង្គភាពយោធភូមិភាគទី៩ |
| ៧-វរសេនីយ៍ឯក | NGUYEN THANH HAI | អង្គភាពយោធភូមិភាគទី៩ |
| ៨-វរសេនីយ៍ឯក | NGUYEN VAN TRI | អង្គភាពយោធភូមិភាគទី៩ |
| ៩-វរសេនីយ៍ឯកបំរុង | KIM DUYEN | អង្គភាពយោធភូមិភាគទី៩ |
| ១០-វរសេនីយ៍ឯកបំរុង | NGUYEN CONG NGOC | អង្គភាពយោធភូមិភាគទី៩ |
| ១១-វរសេនីយ៍ឯកបំរុង | PHAM VAN KIEN | អង្គភាពយោធភូមិភាគទី៩ |

| | | |
|---|---|---|
| ១២-វរសេនីយ៍ត្រី | LE VAN MINH | អង្គភាពយោធភូមិភាគទី៩ |
| ១៣-អនុសេនីយ៍ឯក | THACH HOANG MINH QUAN | អង្គភាពយោធភូមិភាគទី៩ |
| ១៤-អនុសេនីយ៍ឯកបំរុង | LE DOAN QUANG NGHIA | អង្គភាពយោធភូមិភាគទី៩ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងនាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៣១ [illegible] ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ២៩៨១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ចំនួន ១១គ្រឿង ជូនសប្បុរសជន ចំនួន ១១រូប ដែលបានបរិច្ចាគកម្លាំងកាយចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង សមិទ្ធផលនានា នៅវត្តសិរីមង្គលសុទ្ធារាម ស្ថិតនៅក្នុងសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

១- លោក ស៊ាង សេងហុក សប្បុរសជន

២- លោក ឡាយ អ៊ុយ សប្បុរសជន

៣- លោក ជា តារា សប្បុរសជន

៤- លោក ឯក ចន្ថា សប្បុរសជន

៥- លោក សុក ស៊ីន់ សប្បុរសជន

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

១- លោកស្រី ជាវ ខួនហ៊ួយ សប្បុរសជន

២- លោក ជា វណ្ណជា សប្បុរសជន

៣- លោក គាត ហ៊ុល សប្បុរសជន

៤- លោក លឹម យាង សប្បុរសជន

៥- លោក **អួយ ឃុនឡេង** សប្បុរសជន

៦- លោក **សាន ស៊ានហូ** សប្បុរសជន

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។/

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ២៩៨២ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ៣៥គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ៣៥រូប ដែលបានបរិច្ចាគកម្លាំងកាយចិត្ត ព្រមទាំងធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាង សមិទ្ធផលនានានៅវត្តសិរីមង្គលសុទ្ធារាម ស្ថិតនៅក្នុងសង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | ព្រះសោភុនធម្មវង្ស | | បច្ច័យ ១១.០៥០ ដុល្លារ |
| ២- | ព្រះគ្រូធម្មធរ | ប៊ុន ស៊ីម | បច្ច័យ ១០.២០០ ដុល្លារ |
| ៣- | ឧបាសិកា | ទូច ខ៊ែត | សប្បុរសជន ថវិកា ១៣.៥០០ ដុល្លារ |
| ៤- | លោក | អ៊ុំ សុផល | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ៥- | ព្រះតេជគុណ | សែម ប៊ុនធី | បច្ច័យ១០.០៥០ ដុល្លារ |
| ៦- | ព្រះតេជគុណ | ណយ ណេត | បច្ច័យ ១០.២០០ ដុល្លារ |
| ៧- | លោក | កៅ ប៊ុនសេង | សប្បុរសជន ថវិកា ១៣.០០០ ដុល្លារ |
| ៨- | លោក | ង៉េះ មឿន | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ៩- | អ្នកស្រី | សុខ ប៊ុនរ៉េត | សប្បុរសជន ថវិកា ១០.០១០ ដុល្លារ |
| ១០- | លោក | គុយ ឌី | សប្បុរសជន ថវិកា ១០.០១០ ដុល្លារ |

| | | | |
|---|---|---|---|
| ១១- | អ្នកស្រី | ឆាំង សុខលីម | សប្បុរសជន ថវិកា ១០.០៥០ ដុល្លារ |
| ១២- | អ្នកស្រី | ទ៉ាត់ សំអាង | សប្បុរសជន ថវិកា ១០.៥០០ ដុល្លារ |
| ១៣- | លោក | ឆិត្យ ឧត្តម | សប្បុរសជន ថវិកា ១០.០៩៩ ដុល្លារ |
| ១៤- | លោក | ថៃ អ៊ូ | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ១៥- | លោក | លីម គិច | សប្បុរសជន ថវិកា ១២.៥០០ ដុល្លារ |
| ១៦- | ឧបាសិកា | យ៉ីក ណាត | សប្បុរសជន ថវិកា ១០.០៥០ ដុល្លារ |
| ១៧- | លោក | ខ្លូត ជា | សប្បុរសជន ថវិកា ១០.១០០ ដុល្លារ |
| ១៨- | លោក | គុជ សុវណ្ណ | សប្បុរសជន ថវិកា ១០.០៩០ ដុល្លារ |
| ១៩- | លោក | ឈរ ស៊ុនលី | សប្បុរសជន ថវិកា ១០.១០០ ដុល្លារ |
| ២០- | លោក | ស៊ាម ផេង | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ២១- | លោក | នីវ យ៉ាន | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ២២- | លោក | ឆម ស៊ុន | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |
| ២៣- | លោក | ហេង ឈុនធី | សប្បុរសជន ថវិកា ១០.០០០ ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | ម៉ែន ទិន | សប្បុរសជន ថវិកា ៥.៥០០ ដុល្លារ |
| ២- | លោក | គីម ប៊ុនអ៊ី | សប្បុរសជន ថវិកា ៥.១០០ ដុល្លារ |
| ៣- | លោក | ទ័ន សារ៉េត | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |
| ៤- | អ្នកស្រី | ម៉ែន សំអូន | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |
| ៥- | អ្នកស្រី | គីម រ័ត្ន | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |
| ៦- | លោក | ឃិន គីមហេង | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |
| ៧- | អ្នកស្រី | លីម ស៊ីវឆ៊ូវ | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |
| ៨- | លោក | ឆាំ ពេជ្រ | សប្បុរសជន ថវិកា ៥.០០០ ដុល្លារ |

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ**

| | | | |
|---|---|---|---|
| ១- | លោក | គាំ រ័ត្នពុទ្ធា | សប្បុរសជន ថវិកា ២.៣០០ ដុល្លារ |
| ២- | លោក | អ៊ឹម ច្រឹក | សប្បុរសជន ថវិកា ២.២០០ ដុល្លារ |
| ៣- | លោក | សុខ ហាក់ | សប្បុរសជន ថវិកា ២.១០០ ដុល្លារ |
| ៤- | កញ្ញា | សុខ គីម | សប្បុរសជន ថវិកា ២.១០០ ដុល្លារ |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នាយកខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ [illegible] ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ...២៤៤......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ សម្រាប់ឆ្នាំ២០១៣

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១០

-បានឃើញក្រឹត្យលេខ ២៤/ក្រ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៩១ ដែលប្រកាសឱ្យប្រើច្បាប់ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៩១ ស្តីពីការបង្កើតពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

-បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩១ ស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ

-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-យោងតាមការងារចាំបាច់ក្នុងការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣

## សម្រេច ៖

**ប្រការ១.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ត្រូវប្រមូលចាប់ពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតដល់ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៣ ។

**ប្រការ២.-** ដើម្បីបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៣ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវបំពេញលិខិតប្រកាសចំនួន ០២ សន្លឹក តាមគំរូឯកភាពរបស់អគ្គនាយកដ្ឋានពន្ធដារ (លើកលែងតែម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ) ព្រមទាំងបង្ហាញ និងប្រគល់ជូនមន្ត្រីដែលមានសមត្ថកិច្ច នូវបង្កាន់ដៃបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ដើម្បីជាភស្តុតាងបញ្ជាក់ថាមធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១២ រួចហើយ ។

**ប្រការ៣.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណា ពុំមានបង្កាន់ដៃបង់ពន្ធបញ្ជាក់ថាបានបង់ពន្ធឆ្នាំ២០១២ទេនោះ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវបង់ប្រាក់ពន្ធសម្រាប់ឆ្នាំ២០១២ និងត្រូវបង់ប្រាក់ពិន័យដែលមានចំនួនស្មើនឹងប្រាក់ពន្ធ (លើកលែងតែម្ចាស់ទោចក្រយានយន្ត និងត្រីចក្រយានយន្តបំពាក់ដោយម៉ាស៊ីនម៉ូតូ) ទើបអនុញ្ញាតឱ្យបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ ឆ្នាំ២០១៣។

**ប្រការ៤.-** ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទណាដែលបាត់បង្កាន់ដៃបង់ពន្ធសម្រាប់ឆ្នាំ២០១២ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនោះ ត្រូវមានលិខិតបញ្ជាក់ថាបានបង់ពន្ធសម្រាប់ឆ្នាំ២០១២រួចហើយ ដែលចេញដោយប្រធានសាខាពន្ធដារខេត្ត-ខណ្ឌនៃទីកន្លែងដែលយានយន្តនោះបានបង់ពន្ធសម្រាប់ឆ្នាំ២០១២ ។

**ប្រការ៥.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ត្រូវកំណត់លើគ្រប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ទៅតាមប្រភេទនីមួយៗ ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I និង II ភ្ជាប់ជាមួយនឹងប្រកាសនេះ ដោយមិនគិតថាជារបស់រដ្ឋ ឬឯកជនឡើយ ។

**ប្រការ៦.-** ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះនេះ ត្រូវបានលើកលែងចំពោះ ៖

- រថយន្តគិលានសង្គ្រោះ រថយន្តពន្លត់អគ្គីភ័យរបស់រដ្ឋ
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ ជាកម្មសិទ្ធិរបស់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ នគរបាលជាតិ ដែលបំរើឱ្យការងារសំរាប់កិច្ចការពារប្រទេស សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម
- មធ្យោបាយដឹកជញ្ជូន និងយានជំនិះ របស់បេសកកម្មទូត ឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ។

**ប្រការ៧.-** ក្រោយពេលបង់ពន្ធបានត្រឹមត្រូវរួចហើយ ម្ចាស់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗត្រូវបានទទួលបង្កាន់ដៃបង់ពន្ធមួយសន្លឹក និងបណ្ណបង់ពន្ធមួយសន្លឹក សំរាប់បិទភ្ជាប់មធ្យោបាយដឹកជញ្ជូន និងយានជំនិះនីមួយៗនោះ ។ បង្កាន់ដៃបង់ពន្ធនេះត្រូវថែរក្សាកុំឱ្យបាត់បង់ និងត្រូវយកជាប់ជាមួយយានយន្តសម្រាប់ទុកបង្ហាញមន្ត្រីត្រួតពិនិត្យដែលមានសមត្ថកិច្ច និងទុកជាឯកសារសម្រាប់បង់ពន្ធឆ្នាំ២០១៤ ។

**ប្រការ៨.-** សម្រាប់ឆ្នាំ២០១៣ បណ្ណបង់ពន្ធដែលត្រូវបិទភ្ជាប់នឹងមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ មានរូបភាព និងលក្ខណៈសំគាល់ដូចខាងក្រោម ៖

**១.បណ្ណរាងសញ្ញាកងចក្រ០៦កាំ ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "**២០១៣**" ។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ពរូបហង្ស មានពណ៌ទឹកប្រាក់ព្រមទាំងមានកម្រងស្លឹកឈើទ្រពីក្រោមតាមចេនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធរថយន្ត**" ឬ "**បណ្ណបង់ពន្ធត្រាក់ទ័រ**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណ និងលេខតំណាងទឹកប្រាក់ពន្ធតាមប្រភេទបណ្ណនីមួយៗ ។ ផ្នែកខាងក្រោយនៃសន្លឹកបណ្ណមានបង្កប់បន្ទះឈីប (Chip) មានរាងកងចក្រ៦កាំ សម្រាប់ការពារការក្លែងបន្លំបណ្ណ (លើកលែងបណ្ណបង់ពន្ធត្រាក់ទ័រ) ។

បណ្ណរាងសញ្ញាកងចក្រនេះមាន១៥ពណ៌គឺ ៖

- បណ្ណពណ៌ផ្កាឈូកប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៣៥ សេះ (៣០.០០០រៀល)
- បណ្ណពណ៌ខ្ចាញ់ក្លាមប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៦៥ សេះ (៤០.០០០រៀល)
- បណ្ណពណ៌លឿងប្រើសម្រាប់ ត្រាក់ទ័រមានកម្លាំង ៨២ សេះ (៥០.០០០រៀល)
- បណ្ណពណ៌ត្រួយចេក(៨០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ
- បណ្ណពណ៌ក្រហម(១០០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងដល់ ១៥០០ ស.ម³ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ ស.ម³ដល់២០០០ស.ម³ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ
- បណ្ណពណ៌ខៀវខ្ចី (១៥០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញដល់ ៣ តោន
  + រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី១៥០០ស.ម³ដល់២០០០ស.ម³គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ
- បណ្ណពណ៌ឈាមជ្រូក(២០០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកអ្នកដំណើរធុនមធ្យមមានកៅអីពី ១៦ ដល់ ២៥ កៅអី
- បណ្ណពណ៌បៃតងចាស់ (២៥០.០០០រៀល)ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញលើសពី ៣ តោន ដល់ ១០ តោន
  + រ៉ឺម៉កសណ្តោង ដល់ ១០ តោន
  + រថយន្តដឹកអ្នកដំណើរធុនធំមានកៅអីលើសពី ២៥
- បណ្ណពណ៌ស្វាយ (៣៦០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី២០០០ស.ម³ដល់ ២៩០០ស.ម³ គិតពីឆ្នាំផលិតលើសពី៥ឆ្នាំ
- បណ្ណពណ៌ខៀវចាស់ (៤៥០.០០០រៀល) ប្រើសម្រាប់ ៖
  + រថយន្តដឹកទំនិញលើសពី ១០ តោន ដល់ ២០ តោន
  + រ៉ឺម៉កសណ្តោងលើសពី ១០ តោន ដល់ ២០ តោន

- បណ្ណពណ៌ទឹកក្រូច (៥០០.០០០រៀល) ប្រើសម្រាប់ ៖

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២០០០ ស.ម៣ ដល់ ២៩០០ ស.ម៣ គិតពី ឆ្នាំផលិតដល់ ៥ឆ្នាំ

- បណ្ណពណ៌ក្រហមរំលេចពណ៌លឿង (៧៥០.០០០រៀល) ប្រើសម្រាប់ ៖

+ រថយន្តដឹកទំនិញលើសពី ២០ តោន

+ រ៉ឺម៉កសណ្តោងលើសពី ២០ តោន

- បណ្ណពណ៌ខៀវរំលេចពណ៌ស្វាយ (១.២០០.០០០រៀល) ប្រើសម្រាប់ ៖

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម៣ ដល់ ៤០០០ ស.ម៣ គិតពីឆ្នាំផលិតលើសពី ៥ឆ្នាំ

- បណ្ណពណ៌ខៀវរំលេចពណ៌ទឹកក្រូច (១.៦០០.០០០រៀល)ប្រើសម្រាប់ ៖

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ២៩០០ស.ម៣ ដល់ ៤០០០ ស.ម៣ គិតពីឆ្នាំផលិតដល់ ៥ឆ្នាំ

- បណ្ណពណ៌បៃតងចាស់រំលេចពណ៌បៃតងខ្ចី (២.០០០.០០០រៀល)ប្រើសម្រាប់ ៖

+ រថយន្តទេសចរណ៍ទំហំស៊ីឡាំងលើសពី ៤០០០ ស.ម៣ ឡើងទៅ

**២. បណ្ណរាងត្រីកោណ ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**" និងលេខ "២០១៣"។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ពរូបហង្សមានពណ៌ទឹកប្រាក់ព្រមទាំងមានកំរងស្លឹកឈើទ្រពីក្រោមតាមរចនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធ ទោចក្រយានយន្ត**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណនិងលេខតំណាងទឹកប្រាក់ពន្ធតាមប្រភេទបណ្ណនីមួយៗ។

បណ្ណរាងត្រីកោណនេះ មាន៤ពណ៌គឺ ៖

- បណ្ណពណ៌ខៀវរំលេចពណ៌ខៀវខ្ចី និងពណ៌ទឹកក្រូច (៣.០០០រៀល) ប្រើសម្រាប់ ៖

+ ទោចក្រយានយន្តទំហំពិស្តុង ដល់ ៧០ សម៣

- បណ្ណពណ៌ក្រហមរំលេចពណ៌បៃតង និងពណ៌លឿង (៤.៥០០រៀល) ប្រើសម្រាប់ ៖

+ ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ៧០ សម៣ ទៅ ១២៥ សម៣

- បណ្ណពណ៌ត្នោតចេករំលេចពណ៌លឿង និងពណ៌ខៀវខ្ចី (៧.៥០០រៀល) ប្រើសម្រាប់ ៖

+ ទោចក្រយានយន្តមានទំហំពិស្តុងលើសពី ១២៥ សម៣ ឡើងទៅ

- បណ្ណពណ៌លឿងរំលេចពណ៌ក្រហម និងពណ៌ត្នោតចេក (១៥.០០០រៀល) ប្រើសម្រាប់ ៖

+ ត្រីចក្រយានយន្ត និងម៉ូតូរ៉ឺម៉កដឹកទំនិញ ឬអ្នកដំណើរ (បំពាក់ដោយម៉ាស៊ីនម៉ូតូ)

**៣. បណ្ណរាងពងក្រពើ៖**

នៅផ្នែកខាងលើនៃបណ្ណមានបោះពុម្ពអក្សរ "**ព្រះរាជាណាចក្រកម្ពុជា**" "**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**" "**អគ្គនាយកដ្ឋានពន្ធដារ**"និងលេខ "២០១៣"។ ផ្នែកកណ្តាលបណ្ណមានបោះពុម្ពរូបហង្សពណ៌ទឹកប្រាក់ព្រមទាំងមានកំរងស្លឹកឈើទ្រពីក្រោមតាមរចនាបថអង្គរ និងអក្សរ "**បណ្ណបង់ពន្ធជលយាន**" ។ នៅផ្នែកខាងក្រោមបណ្ណមានបោះពុម្ព Barcode ដោយអមជាមួយនូវលេខរៀង៧ខ្ទង់របស់បណ្ណនីមួយៗ។

បណ្ណរាងពងក្រពើនេះមាន៣ពណ៌គឺ ៖

- បណ្ណពណ៌ត្នោតចេកប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០.០០០ រៀល ដល់ ៧០.០០០រៀល

- បណ្ណពណ៌ខៀវ ប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ១០០.០០០រៀល ដល់ ៥០០.០០០រៀល

- បណ្ណពណ៌ទឹកក្រូច ប្រើសម្រាប់ ៖

+ ជលយាន ឬជលយានយន្ត ដែលមានប្រាក់ពន្ធត្រូវបង់ចំនួន ៦០០.០០០រៀល ដល់ ១.២០០.០០០រៀល

**ប្រការ៩**.- ដោយឡែក សម្រាប់ការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ចំពោះរថយន្តដឹកទំនិញ និងរ៉ឺម៉ក-សណ្តោង ការកំណត់ចំនួនប្រាក់ពន្ធត្រូវផ្អែកតាមទម្ងន់សរុប ដែលរួមមានទម្ងន់រថយន្តទទេ និង ទម្ងន់ផ្ទុក (ទំនិញ-មនុស្ស) ។

-ចំពោះរថយន្តដែលបំប្លែងមកពីគោយន្ត និង រថយន្តកែច្នៃកង់បី (បំពាក់ដោយម៉ាស៊ីនរថយន្ត) ត្រូវកំណត់ជា រថយន្តដឹកទំនិញដល់ ៣ តោន និងត្រូវបង់ ១៥០,០០០រៀល

- រីឯរថយន្តដឹកទំនិញធុនធ្ងន់ដែលមានភ្លៅ ៣ កង់ ១០ ប្រាក់ពន្ធត្រូវបង់ ៧៥០,០០០រៀល
- រថយន្តដឹកទំនិញដែលមានភ្លៅ ៣ កង់ ៦ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០រៀល
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៨ ប្រាក់ពន្ធត្រូវបង់ ៤៥០,០០០រៀល និង
- រ៉ឺម៉កសណ្តោងដែលមានភ្លៅ ២ កង់ ៤ ប្រាក់ពន្ធត្រូវបង់ ២៥០,០០០រៀល ។

**ប្រការ១០**.- រថយន្តដឹកទំនិញធុនតូច(PICK UP) ដែលមានទ្វារ៤ (ពីរបាំង) ៖

- ចាត់ទុកជារថយន្តទេសចរណ៍ ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតដល់០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទំហំស៊ីឡាំងដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ II ភ្ជាប់ជាមួយនឹងប្រកាសនេះ ។
- ចាត់ទុកជារថយន្តដឹកទំនិញធុនតូច ចំពោះរថយន្តមានអាយុកាលគិតពីឆ្នាំផលិតលើសពី ០៧ឆ្នាំ នឹងត្រូវបង់ពន្ធតាមទំងន់ផ្ទុកទំនិញរបស់រថយន្ត ដូចមានចែងក្នុងតារាងឧបសម្ព័ន្ធ I ។

**ប្រការ១១**.- យានយន្តគ្រប់ប្រភេទ ដែលមានបណ្ណសម្គាល់យានយន្ត ប៉ុន្តែមិនបានបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១២ ហើយបានលក់ទៅឱ្យអ្នកផ្សេង ក្នុងករណីនេះម្ចាស់យានយន្តត្រូវបង់ពន្ធសម្រាប់ឆ្នាំ២០១២ និងបង់ប្រាក់ពិន័យស្មើនឹងប្រាក់ពន្ធ ទើបអនុញ្ញាតឱ្យបង់ពន្ធសម្រាប់ឆ្នាំ២០១៣ ។

**ប្រការ១២**.- មធ្យោបាយដឹកជញ្ជូនដែលជាទ្រព្យសកម្មរបស់សហគ្រាសជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវមកបំពេញលិខិតប្រកាសតាមគំរូដោយឡែក និងបង់ពន្ធនៅអង្គភាពពន្ធដារដែលសហគ្រាសបានប្រកាសបង់ពន្ធ-អាករ ជារៀងរាល់ខែ ។

**ប្រការ១៣**.- ចាប់ពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១៣ នេះតទៅ អង្គភាពពន្ធដារត្រូវធ្វើការត្រួតពិនិត្យ និងផាកពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់ចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទទាំងឡាយណា ដែលមិនបានបង់ពន្ធសម្រាប់ឆ្នាំ២០១៣ ដូចបានកំណត់ក្នុងប្រការ១ ខាងលើ ។

ប៉ុន្តែចំពោះមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ ដែលទើបដាក់អោយធ្វើចរាចរនៅក្រោយថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១៣ ត្រូវមានវិក្កយបត្របញ្ជាក់ ឬឯកសារផ្សេងៗចេញដោយអ្នក

លក់អមដោយបង្កាន់ដៃបង់ពន្ធនាំចូល ឬបណ្ណសម្គាល់យានយន្ត ភ្ជាប់ជាមួយលិខិតប្រកាសសុំបង់ពន្ធ និងត្រូវមកប្រកាសបង់ពន្ធនៅតាមទីស្នាក់ការពន្ធដារ ឬទីកន្លែងប្រមូលពន្ធដែលកំណត់ដោយសាខាពន្ធដារខេត្ត-ខណ្ឌ នៅរៀងរាល់ថ្ងៃធ្វើការ ។ បើពុំមកប្រកាសសុំបង់ពន្ធក្នុងរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលដាក់ឱ្យធ្វើចរាចរ ត្រូវពិន័យចំនួនមួយដងស្មើប្រាក់ពន្ធបន្ថែមលើប្រាក់ពន្ធដែលត្រូវបង់សម្រាប់ឆ្នាំ២០១៣ នេះ ។

**ប្រការ១៤**.- ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

***កន្លែងទទួល ៖***

- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជ្រាប"
- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលារាជធានី-ខេត្ត "ដើម្បីជ្រាបជាពត៌មាន"
- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់សាខាពន្ធដារខេត្ត-ខណ្ឌ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ..................សហវ.....

# តារាងឧបសម្ព័ន្ធស្តីពីប្រាក់ពន្ធត្រូវកំណត់
# ចំពោះមធ្យោបាយដឹកជញ្ជូន និង យានជំនិះគ្រប់ប្រភេទ
# ( តារាងឧបសម្ព័ន្ធទី ! )

ភ្ជាប់ជាមួយប្រកាសលេខ...១៤៤........សហវ.ប្រក ចុះថ្ងៃទី.១៣..ខែ.កុម្ភៈ....ឆ្នាំ២០១៣ របស់
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ឯកតា៖ រៀល

| ប្រភេទមធ្យោបាយដឹកជញ្ជូន និង យានជំនិះ | កំរិតប្រាក់ពន្ធសម្រាប់១ឆ្នាំ គុណ មួយគ្រឿង | |
|---|---|---|
| - រថយន្តដឹកទំនិញមានទម្ងន់សរុប [ទម្ងន់រថយន្តទទេនិងទម្ងន់ផ្ទុក (ទំនិញ និងមុនស្ស)]៖ | | |
| + ដល់ ៣ តោន | 150 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រ៉ឺម៉កសណ្ដោងដែលមានទម្ងន់សរុប (រ៉ឺម៉កនិងទំនិញ) ៖ | | |
| + ដល់ ១០ តោន | 250 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 450 000 | |
| + លើសពី ២០ តោន | 750 000 | |
| - រថយន្តដឹកអ្នកដំណើរមានកៅអីដល់ ១៥ កៅអី | 150 000 | |
| - រថយន្តដឹកអ្នកដំណើរធុនមធ្យម មានកៅអីពី ១៦ កៅអី ដល់ ២៥ កៅអី | 200 000 | |
| - រថយន្តដឹកអ្នកដំណើរធុនធំ មានកៅអីលើសពី ២៥ កៅអី | 250 000 | |
| - រថយន្តទេសចរណ៍ គ្រប់ប្រភេទ | គិតពីឆ្នាំផលិត | |
| | ដល់ ៥ ឆ្នាំ | លើសពី ៥ ឆ្នាំ |
| + ទំហំស៊ីឡាំងដល់ ១៥០០ ស.ម៣ (ដល់ ១.៥ លីត្រ) | 100 000 | 80 000 |
| + ទំហំស៊ីឡាំងលើសពី១៥០០ស.ម៣ដល់ ២០០០ស.ម៣ (លើសពី ១.៥ដល់២.០លីត្រ) | 150 000 | 100 000 |

| | | |
|---|---|---|
| + ទំហំស៊ីឡាំងលើសពី ២០០០ស.ម៣ ដល់ ២៩០០ស.ម៣(លើសពី ២.០ ដល់២.៩លីត្រ) | 500 000 | 360 000 |
| + ទំហំស៊ីឡាំងលើសពី ២៩០០ ស.ម៣ ដល់ ៤០០០ ស.ម៣(លើសពី ២.៩ ដល់៤.០លីត្រ) | 1 600 000 | 1 200 000 |
| + ទំហំស៊ីឡាំងលើសពី ៤០០០ ស.ម៣ ឡើងទៅ (លើសពី ៤.០លីត្រ) | 2 000 000 | |
| - ត្រាក់ទ័រកម្លាំង ៣៥ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 30 000 | |
| - ត្រាក់ទ័រកម្លាំង ៦៥ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 40 000 | |
| - ត្រាក់ទ័រកម្លាំង ៨២ សេះ និងគ្រឿងចក្រប្រហាក់ប្រហែល | 50 000 | |
| - ទោចក្រយានយន្តទំហំពិសស្តុងដល់ ៧០ ស.ម៣ | 3 000 | |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី៧០ ស.ម៣ ដល់១២៥ ស.ម៣ | 4 500 | |
| - ទោចក្រយានយន្តទំហំពិសស្តុងលើសពី ១២៥ ស.ម៣ ឡើងទៅ | 7 500 | |
| - ត្រីចក្រយានយន្តដឹកទំនិញ ឬ អ្នកដំណើរ | 15 000 | |
| <u>ជលយាន ឬជលយានយន្ត ផ្លូវទន្លេ</u> ៖ | | |
| - ជលយានដឹកទំនិញ ៖ | | |
| + ដល់ ៣ តោន | 50 000 | |
| + លើសពី ៣ តោន ដល់ ១០ តោន | 100 000 | |
| + លើសពី ១០ តោន ដល់ ២០ តោន | 200 000 | |
| + លើសពី ២០ តោន | 300 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ២០ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 200 000 | |
| - កប៉ាល់ដឹកអ្នកដំណើរបណ្តោយលើសពី ៣០ ម៉ែត្រ ឡើងទៅ | 300 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងដល់ ៥០ សេះ | 20 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 30 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 50 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ១៥០ សេះ ដល់ ២០០ សេះ | 60 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២០០ សេះ ដល់ ២៥០ សេះ | 180 000 | |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២៥០ សេះ ឡើងទៅ | 300 000 | |
| - កាណូតនេសាទមានកម្លាំងដល់ ៥០ សេះ | 10 000 | |

| | |
|---|---|
| - កាណូតនេសាទមានកម្លាំងលើសពី ៥០ សេះ ដល់ ១០០ សេះ | 20 000 |
| - កាណូតនេសាទមានកម្លាំងលើសពី ១០០ សេះ ដល់ ១៥០ សេះ | 30 000 |
| - ទូកម៉ាស៊ីនចំហៀង " ជើងបង្កង " | 10 000 |
| - អូប័រមានកម្លាំងដល់ ២៥ សេះ | 150 000 |
| - អូប័រមានកម្លាំងលើសពី ២៥ សេះ ដល់ ៤០ សេះ | 200 000 |
| - អូប័រមានកម្លាំងលើសពី ៤០ សេះ ដល់ ៨០ សេះ | 300 000 |
| - អូប័រមានកម្លាំងលើសពី ៨០ សេះ ដល់ ២០០ សេះ | 400 000 |
| - អូប័រមានកម្លាំងលើសពី ២០០ សេះ ឡើងទៅ | 500 000 |
| <u>ជលយាន ឬជលយានយន្ត ផ្លូវសមុទ្រ</u> ៖ | |
| - ទូកដឹកអ្នកដំណើរបណ្តោយដល់ ២០ ម៉ែត្រ | 100 000 |
| - ទូកដឹកអ្នកដំណើរបណ្តោយពី ២១ ម៉ែត្រ ដល់ ៣០ ម៉ែត្រ | 150 000 |
| - ទូកដឹកទំនិញដល់ ១០០ តោន | 200 000 |
| - ទូកនេសាទដែលមានកម្លាំងដល់ ៩ សេះ | 10 000 |
| - ទូកនេសាទដែលមានកម្លាំងពី ១០ សេះ ដល់ ២០ សេះ | 15 000 |
| - ទូកនេសាទដែលមានកម្លាំងលើសពី ២០ សេះ ដល់ ៤០ សេះ | 25 000 |
| - ទូកនេសាទដែលមានកម្លាំងលើសពី ៤០ សេះ ដល់ ៨០ សេះ | 50 000 |
| - ទូកនេសាទដែលមានកម្លាំងលើសពី ៨០ សេះ ដល់ ១៥០សេះ | 70 000 |
| - ទូកនេសាទដែលមានកម្លាំងលើសពី ១៥០ សេះ ឡើងទៅ | 100 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) ដល់ ១២ សេះ | 10 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង)លើសពី ១២ សេះដល់៥០ សេះ | 20 000 |
| - ទូកនេសាទម៉ាស៊ីនចំហៀង (ជើងបង្កង) លើសពី ៥០ សេះ ឡើងទៅ | 50 000 |
| - កប៉ាល់ដឹកទំនិញដែលផ្ទុកបានដល់ ១.០០០ តោន | 300 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ១.០០០ តោន ដល់ ២.០០០ តោន | 750 000 |
| - កប៉ាល់ដឹកទំនិញផ្ទុកបានលើសពី ២.០០០ តោន ឡើងទៅ | 1 200 000 |
| - កប៉ាល់នេសាទមានកម្លាំងដល់ ១៥០ សេះ | 300 000 |
| - កប៉ាល់នេសាទមានកម្លាំងលើសពី ១៥០ សេះ ដល់ ២៥០ សេះ | 400 000 |

| | |
|---|---|
| - កប៉ាល់នេសាទមានកម្លាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 600 000 |
| - កប៉ាល់នេសាទមានកម្លាំងលើសពី ៥០០ សេះ ឡើងទៅ | 1 200 000 |
| - កប៉ាល់សណ្តោងមានកម្លាំងដល់ ២៥០ សេះ | 200 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ២៥០ សេះ ដល់ ៥០០ សេះ | 400 000 |
| - កប៉ាល់សណ្តោងមានកម្លាំងលើសពី ៥០០ សេះ ឡើងទៅ | 600 000 |

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៣

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ .................... សហវ.....

## ឧបសម្ព័ន្ធកំណត់ទំហំស៊ីឡាំងរបស់រថយន្តទេសចរណ៍

( តារាងឧបសម្ព័ន្ធទី II )

ភ្ជាប់ជាមួយប្រកាសលេខ ២៤៤..... ប្រក.សហវ ចុះថ្ងៃទី ១៣.. ខែ .កុម្ភៈ... ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

| ល.រ | រថយន្តទេសចរណ៍ | ទំហំស៊ីឡាំងគិតជា ស.ម³ "CC" | ទំហំស៊ីឡាំងគិតជាលីត្រ (១លីត្រ=១០០០ស.ម³) | ប្រាក់ពន្ធត្រូវបង់ | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | គិតពីឆ្នាំផលិត ដល់ ៥ឆ្នាំ | គិតពីឆ្នាំផលិត លើសពី ៥ ឆ្នាំ | |
| ១ | រថយន្តទេសចរណ៍ | ដល់ ១ ៥០០ស.ម³ | ដល់ ១.៥ | ១០០ ០០០ រៀល | ៨០ ០០០ រៀល | |
| ២ | រថយន្តទេសចរណ៍ | លើសពី ១ ៥០០ស.ម³ ដល់ ២០០០ ស.ម³ | លើស ១.៥ ដល់ ២.០ | ១៥០ ០០០ រៀល | ១០០ ០០០ រៀល | |
| ៣ | រថយន្តទេសចរណ៍ | លើសពី ២ ០០០ស.ម³ ដល់ ២ ៩០០ ស.ម³ | លើស ២.០ ដល់ ២.៩ | ៥០០ ០០០ រៀល | ៣៦០ ០០០ រៀល | |
| ៤ | រថយន្តទេសចរណ៍ | លើសពី ២ ៩០០ស.ម³ ដល់ ៤ ០០០ ស.ម³ | លើសពី២.៩ដល់ ៤.០ | ១ ៦០០ ០០០ រៀល | ១ ២០០ ០០០រៀល | |
| ៥ | រថយន្តទេសចរណ៍ | លើសពី ៤ ០០០ស.ម³ឡើងទៅ | លើសពី ៤.០ | ២ ០០០ ០០០ រៀល | | |

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០១៣
ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

Pendix 2

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ១៨៥ .......សហវ.ប្រក-ខ្ល

# ប្រកាស
## ស្តីពី
## ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់ការបង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ័ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើតក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា។

**ប្រការ ២.-**

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មានសមាសភាពដូចតទៅ÷

| | | | | |
|---|---|---|---|---|
| ១ | ឯកឧត្តម | **រស់ សីលវ៉ា** | អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២ | ឯកឧត្តម | **កៅ ថាច** | អគ្គនាយករង គណៈកម្មការមូលបត្រកម្ពុជា | អនុប្រធាន |
| ៣ | លោក | **ម៉ី វ៉ាន់** | ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤ | លោក | **ថៃ សភា** | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៥ | លោក | **សុខ សារាវុឌ្ឍ** | ប្រធាននាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦ | លោក | **គីម ផល្លា** | ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧ | លោក | **ជាន់ ផល្លា** | ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨ | លោក | **រ័ត្ន សុវណ្ណនរៈ** | ប្រធាននាយកដ្ឋានត្រួតពិនិត្យឯកសារ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៩ | លោក | **រស់ ភីរុណ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០ | លោក | **ប៊ូ ច័ន្ទភ័ក្ត្រ** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១ | លោក | **យូ វុឌ្ឍី** | អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និងសហប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា | សមាជិក |

| | | | | |
|---|---|---|---|---|
| ១២ | លោក | បាន លីម | អនុប្រធាននាយកដ្ឋាននីតិកម្ម នៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ១៣ | លោក | ឃុន គីមលៀង | ប្រធានការិយាល័យត្រួតពិនិត្យលើឯកសារ នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១៤ | លោក | គុយ បញ្ញា | មន្ត្រីនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១៥ | លោក | ឃុន វាសនា | មន្ត្រីនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ១៦ | លោក | ធីង ចន្ថា | ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | លេខាធិការ |

**ប្រការ ៣ .-**

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មានភារកិច្ចដូចខាងក្រោម÷

- វាយតម្លៃអំពីសភាពការណ៍ និងការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក
- សិក្សា និងវិភាគស្ថានភាពវិបត្តិហិរញ្ញវត្ថុដែលអាចកើតមានឡើងជាយថាហេតុ ទាំងនៅក្នុងសកលលោក តំបន់ និងក្នុងប្រទេស និងផលប៉ះពាល់មកលើកម្ពុជា
- សិក្សា និងលើកអនុសាសន៍អំពីការរៀបចំយន្តការ ដើម្បីទប់ស្កាត់ និងដោះស្រាយវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ និង
- ទំនាក់ទំនង និងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិ និងដៃគូពាក់ព័ន្ធផ្សេងទៀតក្នុងការអភិវឌ្ឍការងារក្នុងក្របខ័ណ្ឌនេះ។

**ប្រការ ៤ .-**

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន និងមានការិយាល័យទីផ្សារហិរញ្ញវត្ថុនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាជំនួយការ។

**ប្រការ ៥ .-**

សមាជិកនៃក្រុមការងារសិក្សាស្រាវជ្រាវ សម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជាទាំងអស់ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្តមាន។

**ប្រការ ៦ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា អគ្គនាយកគណៈកម្មការមូលបត្រកម្ពុជា និងសាមីខ្លួនដូចមានក្នុងប្រការ២ មានភារកិច្ចអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣

គាត ឈន់

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប"
- ដូចប្រការ២
  " ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ[illegible] ឆ្នាំ២០១៣

# សារាចរណែនាំ
## ស្ដីពី
## គោលការណ៍ និងនីតិវិធីផ្ដល់រង្វាន់លើកទឹកចិត្ត លើការផ្ដល់សេវាសាធារណៈ

ដើម្បីបង្កើនប្រសិទ្ធភាពនៃការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ស្របតាមក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងអនុវត្តឱ្យបានម៉ឺងម៉ាត់នូវប្រកាសរួមស្ដីពីការផ្ដល់សេវាសាធារណៈ និងការផ្ដល់រង្វាន់លើកទឹកចិត្ត របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ដោយមានការចូលរួមរៀបចំដោយអង្គភាពប្រឆាំងអំពើពុករលួយ និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ក្នុងស្មារតីទទួលខុសត្រូវជានាឱ្យការផ្ដល់ និងទទួលសេវាសាធារណៈ ការធ្វើសេវាកម្ម ការប្រកបអាជីវកម្ម ក៏ដូចជាការធ្វើពាណិជ្ជកម្មនានាក្នុងព្រះរាជាណាចក្រកម្ពុជា ដំណើរការដោយរលូនប្រកបដោយភាពប្រកួតប្រជែង លុបបំបាត់អំពើពុករលួយ ព្រមទាំងចៀសវាងការថ្នាំងថ្នាក់របស់ប្រជាជន អាជីវករ និងពាណិជ្ជករ ដែលប្រើប្រាស់សេវាសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំដូចតទៅ ៖

### ផ្នែកទី១
### អំពីគោលការណ៍

១- ផ្ដល់រង្វាន់លើកទឹកចិត្តជូនក្រសួង ស្ថាប័ន ដែលបំពេញភារកិច្ចគ្រប់គ្រង ប្រមូលចំណូលពីការផ្ដល់សេវាសាធារណៈ និងការផាកពិន័យ សម្រាប់ឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។

២- អនុញ្ញាតឱ្យរដ្ឋបាលកណ្ដាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន កាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត ដោយកាត់យកពីប្រាក់ចំណូលដែលប្រមូលបាន ផ្អែកទៅតាមសមាមាត្រដែលកំណត់ដោយប្រកាសរួមស្ដីពីការផ្ដល់រង្វាន់លើកទឹកចិត្ត។ ចំណែកប្រាក់រង្វាន់ដែលបានកាត់ទុកនេះ ត្រូវបានចាត់ទុកថាជាប្រាក់បុរេប្រទាន ដែលបានបើកផ្ដល់ដោយថវិកាជាតិ និងត្រូវរក្សាទុកនៅក្នុងរដ្ឋទេយ្យចំណូល។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

៣- ផ្អែកតាមសំណើរបស់អង្គភាពដែលបំពេញភារកិច្ចគ្រប់គ្រង ប្រមូលចំណូលពីសេវាសាធារណៈផ្ទាល់ និងផាកពិន័យ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ននីមួយៗ ត្រូវធ្វើការពិនិត្យ និងសម្រេច ក្នុងការផ្តល់នូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត និងចំណែកសម្រាប់ពង្រឹងយន្តការប្រមូលចំណូលជូនសាមីអង្គភាពទាំងនោះ ឱ្យបានចាប់ពី ៧០% ឡើងទៅនៃប្រាក់រង្វាន់សរុប ដែលអង្គភាពទាំងនោះត្រូវទទួលបាន។ ចំពោះចំណែកប្រាក់រង្វាន់ដែលនៅសល់ រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ននីមួយៗ ត្រូវធ្វើនិយ័តភាពសម្រាប់ការចំណាយឧបត្ថម្ភមន្ត្រីផ្សេងៗទៀត ក្នុងក្រសួង ស្ថាប័នសាមី។ ក្នុងករណីពិសេស ការសម្រេចរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ននីមួយៗ ក្នុងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ជូនដល់អង្គភាពដែលបំពេញភារកិច្ចគ្រប់គ្រង ប្រមូលចំណូលពីសេវាសាធារណៈផ្ទាល់ និងផាកពិន័យ ក៏គប្បីត្រូវគិតពីសមាមាត្រនៃទឹកប្រាក់រង្វាន់លើកទឹកចិត្ត និងចំនួនមន្ត្រីក្នុងអង្គភាពនោះដែរ។

៤- ការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ជូនមន្ត្រីផ្ទៃក្នុងអង្គភាពដែលបំពេញភារកិច្ចគ្រប់គ្រង ប្រមូលចំណូលពីសេវាសាធារណៈផ្ទាល់ និងផាកពិន័យ និងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្ត ជូនមន្ត្រីផ្សេងៗទៀត ត្រូវឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

៥- ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត ត្រូវធ្វើការទូទាត់ប្រចាំខែ (ម្តងក្នុងមួយខែ) លើកលែងតែក្នុងខែនោះមិនមានការប្រមូលចំណូល។

៦- ប្រាក់ចំណូលដែលប្រមូលបាន និងការចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវកត់ត្រាឆ្លុះបញ្ចាំងចំណូលចំណាយ នៅក្នុងកិច្ចប្រតិបត្តិការថវិកាជាតិ។

## ផ្នែកទី២
## អំពីនីតិវិធី

៧- ផ្អែកតាមគោលការណ៍ខាងលើនេះ ក្រសួង ស្ថាប័ននីមួយៗ ដែលទទួលបានការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តលើការងារគ្រប់គ្រង និងប្រមូលចំណូលពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យ ដែលកំណត់ដោយប្រកាសរួមស្តីពីការផ្តល់សេវាសាធារណៈ និងប្រកាសរួមស្តីពីការផ្តល់រង្វាន់លើកទឹកចិត្ត ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម ៖

### ៧.១- ការរៀបចំគម្រោងចំណូល ចំណាយប្រចាំឆ្នាំ

អង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន ត្រូវរៀបចំគម្រោងចំណូលចំណាយប្រចាំឆ្នាំរបស់ខ្លួន ដាច់ដោយឡែកពីគ្នា។ ការគ្រោងគិតចំណូល ត្រូវមានមូលដ្ឋាន ឬទិន្នន័យសមស្រប និងគ្រោងលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដោយផ្អែកតាមតម្លៃសេវាដែលបានកំណត់ដោយប្រកាសរួម។ ការគ្រោងគិតចំណូលនេះ ជាការគ្រោងគិតតួលេខចំណូលសរុប ដោយមិនគិតបញ្ចូលរួមទាំង

ចំណែកប្រាក់ចំណូលដែលត្រូវបំពេញកាតព្វកិច្ចទូទាត់ជូនទៅអតិថិជន ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង នោះឡើយ។ រីឯការគ្រោងចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើការគណនាផ្អែកតាមលទ្ធផលនៃតួលេខចំណូលសរុបដែលបានគ្រោងគិតរួច និងផ្អែកតាមអត្រាផ្តល់ប្រាក់រង្វាន់សរុបនៃប្រភេទសេវាសាធារណៈនីមួយៗ។ ទន្ទឹមនឹងនេះ តួលេខចំណូល ចំណាយដែលបានគ្រោងរួច ត្រូវធ្វើចំណាត់ថ្នាក់ទៅតាមមាតិកាថវិកា ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងចំណូល ចំណាយថវិកាជាតិប្រចាំឆ្នាំ។

### ៧.២- ការប្រមូលចំណូល និងការកាត់ទុកចំណែកប្រាក់រង្វាន់លើកទឹកចិត្ត

ជាទូទៅការប្រមូល ឬការទទួលប្រាក់ចំណូលរបស់អង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ប្រព្រឹត្តទៅក្រោមទិដ្ឋភាពពីរ គឺការប្រមូល ឬការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ និងការប្រមូល ឬការទទួលប្រាក់ចំណូល តាមរយៈការផ្ទេរប្រាក់របស់អតិថិជនដែលប្រើប្រាស់សេវា ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង ចូលគណនីប្រាក់បញ្ញើនៅរតនាគារ ឬធនាគារ ឬគណនីទោលរបស់រតនាគារនៅធនាគារជាតិ ឬសាខា(មិនឆ្លងកាត់រដ្ឋទេយ្យចំណូល)។ រាល់ការប្រមូល ឬការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបោះពុម្ពឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយចុះចំនួនទឹកប្រាក់នៅលើបង្កាន់ដៃបង់ប្រាក់ ស្មើនឹងចំនួនទឹកប្រាក់ជាក់ស្តែងដែលបានទទួលពីអតិថិជន ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង។ ដោយឡែកចំពោះករណីដែលអង្គភាពក្រោមឱវាទក្រសួង ស្ថាប័ន ធ្វើការប្រមូលចំណូល ដែលក្នុងនោះរួមមានទាំងចំណែកប្រាក់ចំណូលរបស់ថវិកាជាតិផង ទាំងចំណែកប្រាក់ចំណូលដែលត្រូវបំពេញកាតព្វកិច្ចទូទាត់ជូនទៅអតិថិជន ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង ផងនោះ ចំនួនទឹកប្រាក់ដែលត្រូវចុះនៅលើបង្កាន់ដៃបង់ប្រាក់ គឺជាចំនួនទឹកប្រាក់ចំណូលសរុបដែលបានទទួល។

ការកាត់ទុកចំណែកប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវធ្វើការគណនាផ្អែកទៅតាមសមាមាត្រប្រាក់រង្វាន់សរុប និងផ្អែកទៅតាមប្រាក់ចំណូលដែលប្រមូលបាន ដែលកំណត់ដោយប្រកាសរួមស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនក្រសួង ស្ថាប័នសាមី ប៉ុន្តែមិនត្រូវគិតបញ្ចូលរួមទាំងចំណែកប្រាក់ចំណូលដែលត្រូវបំពេញកាតព្វកិច្ចទូទាត់ជូនទៅអតិថិជន ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង នោះឡើយ។

ដោយឡែក ចំពោះករណីក្រសួង ស្ថាប័ន ឬអង្គភាពក្រោមឱវាទ ដែលអនុវត្តការប្រមូល ឬការទទួលប្រាក់ចំណូល តាមរយៈការផ្ទេរប្រាក់របស់អតិថិជនដែលប្រើប្រាស់សេវា ឬដៃគូ ឬភាគីនៃកិច្ចសន្យា ឬភាគីនៃកិច្ចព្រមព្រៀង ចូលគណនីប្រាក់បញ្ញើនៅរតនាគារ ឬធនាគារ ឬគណនីទោលរបស់រតនាគារនៅធនាគារជាតិ ឬសាខា(មិនឆ្លងកាត់រដ្ឋទេយ្យចំណូល) ត្រូវដកប្រាក់រង្វាន់លើកទឹកចិត្ត តាមរយៈអាណត្តិបើកប្រាក់ ដោយអនុវត្តនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៧.៣- ការបើកផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តពីថវិកាជាតិ

ការកាត់ទុកជាមុននូវចំណែកប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវបានចាត់ទុកថាថវិកាជាតិបានបើកផ្តល់ប្រាក់បុរេប្រទាន ជូនអង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន សម្រាប់ចំណាយឧបត្ថម្ភជូនមន្ត្រីដែលបំពេញភារកិច្ចផ្ទាល់ និងមន្ត្រីផ្សេងៗទៀត ព្រមទាំងសម្រាប់ពង្រឹងយន្តការប្រមូលចំណូលឱ្យមានប្រសិទ្ធភាព។ ប្រាក់បុរេប្រទាននេះ មិនតម្រូវឱ្យសាមីអង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ន ធ្វើលិខិតស្នើសុំមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឡើយ។

៧.៤- ការចំណាយប្រាក់រង្វាន់លើកទឹកចិត្ត

ការចំណាយប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវគោរពតាមចំណុចទី៣ និងចំណុចទី៤ នៃសារាចរណែនាំនេះ។ ចំនួនលើកនៃការបែងចែក និងបើកប្រាក់ឧបត្ថម្ភប្រចាំខែជូនមន្ត្រីរាជការ និងរាល់ការចំណាយសម្រាប់ពង្រឹងយន្តការប្រមូលចំណូល ត្រូវផ្អែកតាមស្ថានភាពជាក់ស្តែងនៃតម្រូវការចាំបាច់ និងបន្ទាន់នានា ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងជំរុញឱ្យមានតម្លាភាពក្នុងការផ្តល់សេវាសាធារណៈ។

ចំពោះប្រាក់រង្វាន់លើកទឹកចិត្តដែលជាចំណែករបស់រដ្ឋបាលកណ្តាល និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលសាមីអង្គភាពរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗ បានកាត់ទុកជាមុន និងរក្សាទុកនៅក្នុងរដ្ឋទេយ្យចំណូលរបស់ខ្លួននោះ ត្រូវធ្វើការបើកផ្តល់ជូននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបើកផ្តល់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត នៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ ទៅតាមអត្រារង្វាន់លើកទឹកចិត្ត ដែលបានកំណត់ដោយប្រកាសរួម។

៧.៥- ការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត

ជារៀងរាល់ខែ រដ្ឋទេយ្យករចំណូលនៃរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗ ត្រូវធ្វើការបូកសរុបចំនួនទឹកប្រាក់បុរេប្រទាន ដោយគិតត្រឹមថ្ងៃទី២៥ នៃខែនីមួយៗ និងគិតត្រឹមថ្ងៃទី៣១ ចំពោះខែធ្នូ តាមរយៈការប្រើប្រាស់តារាងស្តីពីការគណនាប្រាក់រង្វាន់ ដែលចំនួនទឹកប្រាក់សរុបនេះត្រូវប្រើជាមូលដ្ឋានសម្រាប់ចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិផង និងចុះនៅក្នុងអាណត្តិបើកប្រាក់ (អាណត្តិនិយ័តកម្ម)ផង។ ការទូទាត់ប្រាក់បុរេប្រទាននេះ ជាការអនុវត្តនីតិវិធីដោយឡែក ដែលមិនតម្រូវចាំបាច់ឱ្យភ្ជាប់មកជាមួយនូវសក្ខីប័ត្រចំណាយជាក់ស្តែងពេញលេញឡើយ។ ប៉ុន្តែ រាល់ការចំណាយប្រាក់បុរេប្រទានរដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗ ត្រូវមានសក្ខីប័ត្រចំណាយត្រឹមត្រូវ។

- ចំពោះរដ្ឋបាលកណ្តាល : រដ្ឋទេយ្យករចំណូល ត្រូវបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ និងអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដែលបានរៀបចំរួច ដោយភ្ជាប់មកជាមួយនូវតារាងស្តីពីការគណនាប្រាក់រង្វាន់

របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក ទៅនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ដើម្បីចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ រួចបញ្ជូនទៅនាយកដ្ឋានហិរញ្ញកិច្ច ដើម្បីបន្តអនុវត្តនីតិវិធីលើការរៀបចំអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) និងចុងក្រោយបញ្ជូនសំណុំឯកសារទាំងនេះព្រមគ្នាក្នុងពេលតែមួយទៅរតនាគារជាតិ ដើម្បីពិនិត្យ និងធ្វើការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត។

- ចំពោះមន្ទីរជំនាញរាជធានី ខេត្ត : រដ្ឋទេយ្យករចំណូល ត្រូវបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ និងអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) ដែលបានរៀបចំរួច ដោយភ្ជាប់មកជាមួយនូវតារាងស្តីពីការគណនាប្រាក់រង្វាន់ របាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ដើម្បីចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រចំណូលថវិកាជាតិ និងបន្តអនុវត្តនីតិវិធីលើការរៀបចំអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម) និងចុងក្រោយបញ្ជូនសំណុំឯកសារទាំងនេះព្រមគ្នាក្នុងពេលតែមួយ ទៅរតនាគាររាជធានី ខេត្ត ដើម្បីពិនិត្យ និងធ្វើការទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត។

៨- ករណីដែលក្រសួង ស្ថាប័ន ឬមន្ទីរជំនាញរាជធានី ខេត្តណាមួយ មិនយកចិត្តទុកដាក់ក្នុងការអនុវត្តនីតិវិធីទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្តឱ្យបានទាន់ពេលវេលា ឬមិនបានរៀបចំសំណុំឯកសារដើម្បីធ្វើការទូទាត់ទេនោះ នឹងត្រូវប្រឈមមុខទៅនឹងការពិន័យរដ្ឋបាលពីប្រមុខរាជរដ្ឋាភិបាល·ជាយថាហេតុ។

## ផ្នែកទី៣
## ការកត់ត្រាតាមដាន និងការទទួលខុសត្រូវ

៩- ការកត់ត្រាតាមដានឆ្លុះបញ្ចាំងចំណូល ចំណាយ លើប្រាក់ចំណូលដែលប្រមូលបាន និងការចំណាយប្រាក់រង្វាន់លើកទឹកចិត្តរបស់រដ្ឋបាលកណ្តាល និងមន្ទីរជំនាញរាជធានី ខេត្ត នៃក្រសួង ស្ថាប័ននីមួយៗ ក្នុងការអនុវត្តនីតិវិធីផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ត្រូវបានកំណត់ដូចតទៅ ៖

៩.១- នៅពេលប្រមូល ឬទទួលបានប្រាក់ចំណូលពីការផ្តល់សេវាសាធារណៈ និងការផាកពិន័យ រដ្ឋទេយ្យករចំណូល ត្រូវកត់ត្រាតាមដានប្រាក់ចំណូលចែកចេញជាពីរចំណែក :

- ចំណែកទី១ : ជាប្រាក់ចំណូលដែលត្រូវបង់ចូលថវិកាជាតិជាសាច់ប្រាក់ ឬជាមូលប្បទានប័ត្រ។ ចំណែកប្រាក់ចំណូលនេះ ជាចំណូលពិត ដែលក្នុងខែនីមួយៗ រដ្ឋទេយ្យករចំណូលត្រូវបង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ដែលជាសក្ខីប័ត្រយោងសម្រាប់កត់ត្រាជាចំណូលថវិកាជាតិ។

- ចំណែកទី២ : ជាប្រាក់ចំណូលដែលចាត់ទុកថាជាប្រាក់បុរេប្រទាន សម្រាប់ចំណាយលើប្រាក់រង្វាន់លើកទឹកចិត្ត។ រដ្ឋទេយ្យករចំណូល ត្រូវរក្សាទុកចំណែកប្រាក់ចំណូលនេះនៅក្នុងរដ្ឋទេយ្យចំណូលសម្រាប់ចំណាយលើប្រាក់រង្វាន់លើកទឹកចិត្ត ហើយអាចដកចំណាយជាបណ្តើរៗ ផ្អែកទៅតាមតម្រូវការចាំបាច់ និងបន្ទាន់នានា ដែលស្ថិតក្រោមការទទួលខុសត្រូវរបស់រដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន សាមី។ ជារៀងរាល់ខែ រដ្ឋទេយ្យករចំណូល ត្រូវបូកសរុបប្រាក់ចំណូលចំណែកទី២ នេះ និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ដើម្បីជាមូលដ្ឋានសម្រាប់កត់ត្រាជាចំណូលថវិកាជាតិ និងសម្រាប់ការអនុវត្តនីតិវិធីទូទាត់លើការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត ។

៩.២- ក្រោយពេលអនុវត្តនីតិវិធីទូទាត់ប្រាក់បុរេប្រទានលើរង្វាន់លើកទឹកចិត្ត សលាកប័ត្រចំណូលថវិកាជាតិនៃចំណូលចំណែកទី២ និងអាណត្តិនិយ័តកម្មចំណាយប្រាក់បុរេប្រទាន ជាសក្ខីប័ត្រយោងសម្រាប់រដ្ឋទេយ្យករចំណូល និងគណនេយ្យករមុខការនៃរតនាគារជាតិ ឬរតនាគាររាជធានី ខេត្ត ធ្វើគណនេយ្យកម្ម ដោយកត់ត្រាព្រមគ្នានៅផ្នែកចំណូលផង និងផ្នែកចំណាយផង លើមូលដ្ឋានចំនួនទឹកប្រាក់សរុបចំណូល ស្មើនឹងសរុបចំណាយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមលើស្មារតីទទួលខុសត្រូវខ្ពស់របស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត ក្នុងការយកចិត្តទុកដាក់អនុវត្តសារាចរណែនាំនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ព្រមជាមួយនឹងការខិតខំប្រឹងប្រែងប្រមូលចំណូលមិនមែនសារពើពន្ធ ដើម្បីកៀគរប្រាក់ចំណូលចូលថវិកាជាតិ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

<u>ចម្លងជូន</u> :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋាន និងនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- រតនាគាររាជធានី ខេត្ត
- ឯកសារ - កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ : ០០២.....សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែកុម្ភៈ ឆ្នាំ ២០១៣

# សេចក្តីណែនាំ
# ស្តីពី
# ការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករចំណូល និងភ្នាក់ងារបើកផ្តល់ របស់ឃុំ សង្កាត់

- យោងប្រកាសលេខ ២៨៥សហវ.ប្រក.ហម ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងប្រកាសលេខ ៤៥២សហវ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតម្រូវការចាំបាច់សម្រាប់បម្រើឱ្យកិច្ចបញ្ជិកាគណនេយ្យថវិកាឃុំ សង្កាត់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមចេញសេចក្តីណែនាំនូវការប្រើប្រាស់គណនីដូចមានខ្លឹមសារខាងក្រោមនេះ៖

១- មេឃុំ ចៅសង្កាត់ត្រូវធ្វើការតែងតាំងស្មៀនឃុំ សង្កាត់ជារដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករចំណូល និងភ្នាក់ងារបើកផ្តល់សម្រាប់ឃុំ សង្កាត់នីមួយៗដោយសេចក្តីសម្រេច ។

២- សេចក្តីសម្រេចស្តីពីការតែងតាំងរដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករចំណូល និងភ្នាក់ងារបើកផ្តល់ ត្រូវធ្វើដោយឡែកពីគ្នា ។

៣- ភ្នាក់ងារបើកផ្តល់របស់ឃុំ សង្កាត់ ត្រូវបើកគណនីប្រាក់បៀវត្ស និងលាភការត្រូវសង(លេខ៤២១) នៅរតនាគាររាជធានី ខេត្ត សម្រាប់បម្រើឱ្យប្រតិបត្តិការចំណូល ចំណាយប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់លាភការផ្សេងៗរបស់ឃុំ សង្កាត់ដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចតែងតាំងភ្នាក់ងារបើកផ្តល់។

៤- រដ្ឋទេយ្យករបុរេប្រទានរបស់ឃុំ សង្កាត់ត្រូវបើកគណនីរដ្ឋទេយ្យករបុរេប្រទាន (លេខ៥៤៣) នៅរតនាគាររាជធានី ខេត្ត សម្រាប់បម្រើឱ្យប្រតិបត្តិការដកប្រាក់រដ្ឋទេយ្យបុរេប្រទានដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចតែងតាំងរដ្ឋទេយ្យករបុរេប្រទាន ។ របៀបគណនាកម្រិតនៃរដ្ឋទេយ្យបុរេប្រទានដែលត្រូវដកការដកប្រាក់ ការចំណាយប្រាក់ និងការទូទាត់ប្រាក់រដ្ឋទេយ្យបុរេប្រទានរបស់ឃុំ សង្កាត់ត្រូវអនុវត្តតាមគោលការណ៍នៃការកាន់កាប់ និងចាត់ចែងលើបេឡាបុរេប្រទានដែលឃុំ សង្កាត់បានអនុវត្តកន្លងមក ។

៥- រដ្ឋទេយ្យករចំណូលរបស់ឃុំ សង្កាត់ត្រូវបើកគណនីរដ្ឋទេយ្យករចំណូល(លេខ៤៧៧) នៅរតនាគាររាជធានី ខេត្ត សម្រាប់បម្រើឱ្យប្រតិបត្តិការចំណូលសាច់ប្រាក់ដែលប្រមូលបានដោយភ្ជាប់មកជាមួយនូវសេចក្តីសម្រេចតែងតាំងរដ្ឋទេយ្យករចំណូល ។ រដ្ឋទេយ្យករចំណូលត្រូវបង់ប្រាក់ដែលប្រមូលបានចូលគណនី



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥.២៣.៧២៤ ៦៦៤ ទូរសារ : ៨៥៥.២៣.៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798
mef_adm@yahoo.com

ចរន្តរបស់ឃុំ សង្កាត់ នៅសាខាធនាគារជាតិនៃកម្ពុជា ឬ សាខាធនាគារពាណិជ្ជដោយភ្ជាប់មកជាមួយនូវសលាកប័ត្របង់ចំណូលថវិកាឱ្យបានឆាប់រហ័ស ។

៦- ក្នុងករណីចាំបាច់ ពេលដែលស្មៀនឃុំ សង្កាត់ អវត្តមានដោយប្រការណាមួយ មេឃុំ ចៅសង្កាត់ត្រូវប្រគល់ភារៈកិច្ចជូនជំទប់ទី១ ចៅសង្កាត់រងទី១ ឬជំទប់ទី២ ចៅសង្កាត់រងទី២ ណាម្នាក់ជំនួសជារដ្ឋទេយ្យករបុរេប្រទាន រដ្ឋទេយ្យករចំណូល និងភ្នាក់ងារបើកផ្តល់ដោយមានការសម្រេចពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

៧- រាល់ខ្លឹមសារដែលផ្ទុយនឹងសេចក្តីណែនាំនេះត្រូវចាត់ទុកជានិរាករណ៍ ។

៨- សេចក្តីណែនាំនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**

- គ្រប់សាលារាជធានី ខេត្ត
- គ្រប់ក្រុង និង ឃុំ សង្កាត់
- អគ្គនាយកដ្ឋានរតនាគារជាតិ
- នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រុមការងារគ្រប់គ្រង និងអនុវត្តអនុកម្មវិធីទី៤ នៃជអ៣
- នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

"ដើម្បីសហការអនុវត្ត"

- លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

"ដើម្បីជូនជ្រាប"

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០១ សហវ.គភ

# បទបញ្ជាផ្ទៃក្នុង
# នៃ
# គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

- យោងតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧
- យោងអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម លេខ៥៦ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មលើកទី១ នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ បានអនុម័តបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលមានខ្លឹមសារដូចខាងក្រោមនេះ ៖

## ជំពូកទី ១
## គណៈកម្មាធិការ

**ប្រការ១.-** គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ហៅកាត់ថា "គ.ស.ហ" បានទទួលការតែងតាំងដោយអនុក្រឹត្យលេខ ៥៦អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| - ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| - អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា | អនុប្រធានប្រចាំការ |
| - តំណាងគណៈកម្មាធិការជាតិប្រឆាំងអំពើភេរវកម្ម | អនុប្រធាន |
| - សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |

- សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងក្រសួងយុត្តិធម៌ សមាជិក
- សមាជិកក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- អគ្គលេខាធិការអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លេខាធិការ

**ប្រការ២**.~ ប្រធាន គ.ស.ហ មានអំណាចផ្ទេរសិទ្ធិឲ្យអនុប្រធានប្រចាំការ កោះអញ្ជើញសមាជិកទាំងអស់ចូលរួមក្នុងអង្គប្រជុំរបស់គ.ស.ហ ។

**ប្រការ៣**.~ កំណត់ហេតុ និងឯកសារដទៃទៀតរបស់ គ.ស.ហ ត្រូវរក្សាទុកនៅលេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយមិនត្រូវធ្វើឲ្យបែកខ្ចរខ្ចាយទៅខាងក្រៅដោយគ្មានការអនុញ្ញាតពីប្រធាន គ.ស.ហ ឡើយ ។

## ជំពូកទី ២
## ការប្រជុំ

**ប្រការ៤**.~ គ.ស.ហ ត្រូវរៀបចំការប្រជុំយ៉ាងហោចណាស់ ០១ (មួយ) ដង ក្នុងមួយឆ្នាំ ឬច្រើនជាងនេះ តាមការស្នើសុំរបស់ប្រធាន ឬអនុប្រធានប្រចាំការ ។

**ប្រការ៥**.~ ប្រធាន ឬអនុប្រធានប្រចាំការ គ.ស.ហ ត្រូវកោះអញ្ជើញសមាជិកនៃ គ.ស.ហ ដើម្បីចូលរួមប្រជុំ ក្នុងរយៈពេលយ៉ាងហោចណាស់ ៥ថ្ងៃធ្វើការ មុនការប្រជុំ ដោយមានបញ្ជាក់ពីរបៀបវារៈ កាលបរិច្ឆេទ និងទីកន្លែងប្រជុំ ។

**ប្រការ៦**.~ លិខិតអញ្ជើញដែលបានបញ្ជូនទៅសមាជិក គ.ស.ហ ត្រូវមានហត្ថលេខាទទួលពីតំណាងសាមីស្ថាប័ន ។

**ប្រការ៧**.~ ឯកសារទាក់ទងនឹងខ្លឹមសារនៃអង្គប្រជុំនីមួយៗ ត្រូវបញ្ជូនទៅសមាជិក គ.ស.ហ ឲ្យបានមុនកាលបរិច្ឆេទប្រជុំ លើកលែងតែឯកសារ ដែលមានលក្ខណៈបន្ទាន់ ។

**ប្រការ៨**.~ រាល់ពេលប្រជុំត្រូវមានបញ្ជីវត្តមាន និងហត្ថលេខារបស់សមាជិកអង្គប្រជុំ ។ ៗ

**ប្រការ៩.~** អង្គប្រជុំរបស់ គ.ស.ហ អាចប្រព្រឹត្តទៅបានលុះត្រាតែមានសមាជិកចូលប្រជុំចាប់ពី ៥នាក់ឡើងទៅ ហើយត្រូវដឹកនាំដោយប្រធាន ឬអនុប្រធានប្រចាំការ ។ ក្នុងករណីអវត្តមានរបស់ប្រធាន ឬអនុប្រធានប្រចាំការ ការប្រជុំត្រូវលើកទៅពេលក្រោយ ។ ក្នុងករណីមិនគ្រប់កូរ៉ុម ប្រធាន ឬអនុប្រធានប្រចាំការត្រូវកោះអញ្ជើញជាថ្មី ដោយរក្សារបៀបវារៈដដែល ។ អង្គប្រជុំអាចសម្រេចការងារដោយមិនគិតពីកូរ៉ុមទេ ។

**ប្រការ១០.~** អង្គប្រជុំរបស់ គ.ស.ហ ពិភាក្សាជាចំហលើខ្លឹមសារនៃរបៀបវារៈនីមួយៗ ហើយអនុម័តដោយវិធីលើកដៃ ។

**ប្រការ១១.~** អង្គប្រជុំត្រូវសម្រេចដោយសម្លេងភាគច្រើននៃសមាជិកវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីសម្លេងស្មើគ្នា សម្លេងរបស់ប្រធានអង្គប្រជុំ ត្រូវមានឧត្តមានុភាព ។

**ប្រការ១២.~** នៅពេលប្រជុំម្តងៗ លេខាធិការត្រូវធ្វើកំណត់ហេតុនៃអង្គប្រជុំ គ.ស.ហ ឲ្យបានច្បាស់លាស់ ហើយត្រូវដាក់ជូនសមាជិក គ.ស.ហ ជាមុននិងចុះហត្ថលេខានៅកិច្ចប្រជុំលើកក្រោយ ។

**ប្រការ១៣.~** ក្រោយពេលប្រជុំនីមួយៗ ប្រធានឬអនុប្រធានប្រចាំការ គ.ស.ហ ត្រូវចេញសេចក្តីជូនដំណឹងជាបន្ទាន់ អំពីលទ្ធផលនៃការប្រជុំ គ.ស.ហ ដើម្បីជាមូលដ្ឋានសម្រាប់យកទៅអនុវត្តឲ្យមានប្រសិទ្ធភាព ។

## ជំពូកទី ៣
## អវសានប្បញ្ញត្តិ

**ប្រការ១៤.~** គ.ស.ហ ត្រូវអនុវត្តឲ្យបានម៉ឺងម៉ាត់នូវបញ្ញត្តិផ្សេងៗនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ។

**ប្រការ១៥.~** បទបញ្ជាផ្ទៃក្នុងនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។៚

ភ្នំពេញ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ប្រធាន គ.ស.ហ**

**គាត ឈន់**

កន្លែងទទួល
- សមាជិក គ.ស.ហ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"